☑改編自：新北市教育局出版
《陪你快樂學柬埔寨語》
□自編

108年新北市各級學校東南亞語文競賽
團體朗讀文稿　柬埔寨國高中組B-2

ចូលរួមពិធីមង្គលការ

ពោល : សុខា នឹងម៉ាក់ បងស្រី ប្អូនស្រី ជិះយន្តហោះទៅប្រទេសកម្ពុជាមួយគ្នាចូលរួមពិធីមង្គលការម៉ីង។

ម៉ាក់ : ថ្ងៃស្អែកគឺជាពិធីមង្គលការម៉ីង ការរៀបពិធីមង្គលការខុសគ្នានឹងនៅតៃវ៉ាន់ កូនៗទាំងអស់អាចនិងមានបទពិសោធន៍ល្អៗ។

សុខា : បងស្រី ប្អូនស្រី:ចាម៉ាក់។

ម៉ាក់: នៅប្រទេសកម្ពុជា ការរៀបពិធីមង្គលការគឺរៀបចំនៅផ្ទះខាងស្រី។

សុខា : បងស្រី ប្អូនស្រី:អ! គួរឱ្យពិសេសណាស់!

ម៉ាក់ : កាលពីមុនការរៀបពិធីមង្គលការរៀបចំរយៈពេលបីថ្ងៃ ឥឡូវភាគច្រើនកាត់បន្ថយនៅត្រឹមតែមួយថ្ងៃថែមមួយព្រឹកទៀតតែប៉ុណ្ណោះទេ។

សុខា : បន្តិចទៀតខ្ញុំទៅមើលកូនកំលោះសិន។

ម៉ាក់ : ចូលគេងពីព្រលប់ទៅ ថ្ងៃស្អែកម៉ីងត្រូវងើបពីព្រលឹម ដើម្បីតែងខ្លួនជាត់មុខម៉ាត់។

សុខា បងស្រី ប្អូនស្រី: រាត្រីសួស្តី!

ពោល : ថ្ងៃទីពីរ

ម៉ាក់ : កូនទាំងអស់គ្នាប្រញាប់ក្រោកឡើង ទៅស្លៀកពាក់សំលៀកបំពាក់ថ្មីរបស់កូន! ម៉ីងរៀបចំខ្លួនជាត់មុខរួចអស់ហើយ។

សុខា : បងស្រី ប្អូនស្រី : (អា!) ប្រញាប់ទៅមើលកូនក្រមុំ។

ប្អូនស្រី : តើកៅអីលាបរបស់ពណ៌មាសធ្វើពីវត្ថុអ្វីទៅ?

ម៉ាក់ : នោះគឺជាជំនូនខាងកូនកំលោះ មាន៣៦គូរ គឺជា៧២ចាន។

សុខា : ប្រញ៉ាប់ឡើង លោកតា លោកយាយ អញ្ជើញចាស់ទុំទៅរៀបចំពិធីសែនដូនតា។!

ម៉ាក់ : កូនកំលោះកូនក្រមុំត្រូវក្រាបសំពះគោរពដឹងគុណទៅកាន់មាតាបិតាទាំងសងខាងបីដង ។

សុខា បងស្រី ប្អូនស្រី:ប្រញ៉ាប់ឡើង ប្រញ៉ាប់ឡើង ។

ពោល : ពេលរសៀល

ប្អូនស្រី : តើហេតុអ្វីបានជាគេកាត់សក់អោយកូនកំលោះកូនក្រមុំ?

ម៉ាក់ : សក់ដែលកាត់ចេញយកទៅទុកក្នុងប្រអប់តូច គឺតំណាងអោយជាការរួមគ្នាជាស្វាមីភរិយា។

ម៉ាក់ : ចាំមួយភ្លេត នៅពេលដែលដុតទានហើយ អ្នកគ្រប់គ្នានឹងយកផ្កាស្លារបាចទៅលើកូនកំលោះកូនក្រមុំ។

សុខា : តើហេតុអ្វីបានជាគេយកខ្សែរអំបោះពណ៌ក្រហមទៅចងទៅលើដៃកូនកំលោះកូនក្រមុំ?

ម៉ាក់ : វាមានន័យថាដួងចិត្តដែរស្អាតស្អំពីរនឹង ព្រមទាំងគ្រួសារពីរបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយគ្នាហើយ។

បងស្រី: លោកតានិយាយថា បន្ទប់មកព្រះសង្ឃនឹងសូត្រមន្តប្រសិទ្ធពរជ័យដល់គូរស្វាមីភរិយាថ្មី អោយមានសុភមង្គលសិរីសួស្តីក្នុងអាពាហ៍ពិពាហ៍។

ពោល : កូនកំលោះកូនក្រមុំអង្គុយក្រាបសំពះព្រះសង្ឃទាំងអស់គ្នា ព្រះសង្ឃចាប់ផ្តើមសូត្រមន្ត។

ប្អូនស្រី : អឺម! បន្ទាប់មកគឺដល់ពេលទទួលភ្ញៀវអាហារពេលល្ងាចហើយ។

បងស្រី : កូនកំលោះកូនក្រមុំស្លៀកឈុតមង្គលការ ឈរទទួលភ្ញៀវនៅមុខរោងការ មើលទៅគួរអោយសមគ្នាណាស់ ។

សុខា ប្អូនស្រី: ការរៀបពិធីមង្គលការរបស់ខ្មែរគួរឱ្យចាប់អារម្មណ៍ខ្លាំងណាស់ ជូនពរ គូរស្វាមីភរិយាថ្មីអោយមានសេចក្តីសុខសិរីសួស្តី!

ម៉ាក់ បងស្រី : ជូនព គូរស្វាមីភរិយាថ្មីរអោយមានសេចក្តីសុខសិរីសួស្តី!